**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សមាជរដ្ឋសភា និងព្រឹទ្ធសភា

លេខ: ០៤៤/០៣ ២៥/ស.ម

# សេចក្តីសម្រេច
# ស្តីពី
# សេដ្ឋកិច្ចក្រៅប្រព័ន្ធ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១១/០០៥ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា នីតិកាលទី៥
- យោងលទ្ធផលនៃសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ ស្តីពីការបោះឆ្នោតជ្រើសតាំងរចនាសម្ព័ន្ធថ្នាក់ដឹកនាំរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣
- យោងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនានារបស់ព្រឹទ្ធសភា នីតិកាលទី៥
- យោងលទ្ធផលនៃសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការនានានៃរដ្ឋសភា នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣
- យោងលិខិតលេខ ២៣៧ លស ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីសេចក្តីស្នើសុំកោះប្រជុំសមាជរដ្ឋសភា និងព្រឹទ្ធសភា ដើម្បីពិភាក្សាលើប្រធានបទសំខាន់ចំនួន៣ របស់ប្រទេសជាតិ
- យោងលទ្ធផលនៃអង្គប្រជុំសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៥

## សម្រេច

**មាត្រា១.-**

សមាជរដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា គាំទ្រទាំងស្រុងនូវយុទ្ធសាស្ត្រជាតិ ស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ ដែលដាក់ចេញដោយរាជរដ្ឋាភិបាល ជាយុទ្ធសាស្ត្រដ៏ត្រឹមត្រូវ ស្របនឹងស្ថានភាពសេដ្ឋកិច្ច និងសង្គមកម្ពុជាបច្ចុប្បន្ន និងទៅអនាគត ក្នុងរយៈពេលនៃអាណត្តិទី៧។

**មាត្រា២..**

សមាជរដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា គាំទ្រទាំងស្រុងនូវការអនុវត្ត វិធានការគន្លឹះនិងផែនការសកម្មភាពទាំងឡាយរបស់រាជរដ្ឋាភិបាលដែលបានអនុវត្តកន្លងមក ស្របនឹងគោលនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដោយផ្តល់នូវផល ប្រយោជន៍ជាក់ស្តែងដល់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងកំពុងបានរួមចំណែកពង្រឹងនិងពង្រីកមូល ដ្ឋានគ្រឹះនៃសេដ្ឋកិច្ចជាតិ។

**មាត្រា៣..**

សមាជរដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា លើកទឹកចិត្តរាជរដ្ឋាភិបាលឱ្យបន្ត អនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ និងវិធានការគន្លឹះ ទាំងឡាយនៃយុទ្ធសាស្ត្រនេះ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យរីកធំធាត់ និងក្លាយជាកម្លាំង ចលករដ៏សំខាន់ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់ទៅនឹង វិបត្តិ។

**មាត្រា៤..**

សមាជរដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា លើកទឹកចិត្តឱ្យព្រឹទ្ធសភា និង រដ្ឋសភា បន្តគាំទ្ររាជរដ្ឋាភិបាលក្នុងការអនុម័តច្បាប់ទាំងឡាយ ដែលជួយដោះស្រាយបញ្ហា ប្រឈម និងឆ្លើយតបតាមតម្រូវការរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

**មាត្រា៥..**

សមាជរដ្ឋសភា និងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សូមថ្លែងអំណរគុណចំពោះស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ប្រជាពលរដ្ឋគ្រប់ ស្រទាប់វណ្ណៈ ដែលបានគាំទ្រចំពោះកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងសូមអំពាវនាវបន្ត ចូលរួមថែរក្សាសន្តិភាពនិងការអភិវឌ្ឍឱ្យបានគង់វង្សនិងមានចីរភាពជានិរន្តន៍។

**មាត្រា៦..**

ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និង ស្ថាប័នមានសមត្ថកិច្ច ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តសេចក្តីសម្រេចនេះ។

**មាត្រា៧.-**

សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្តអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ១២កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៥

**ប្រធានសមាជរដ្ឋសភា និងព្រឹទ្ធសភា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន៖**
-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា
-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា
-រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-ស្ថាប័នមានសមត្ថកិច្ច
"ដើម្បីជូនជ្រាប និងអនុវត្ត "
-ឯកសារ កាលប្បវត្តិ